## សំនួរ និង ចម្លើយ

# វិធានការ

# K

## ប័ណ្ណប្រាក់រដ្ឋាភិបាលសម្រាប់សាលា

ប្រឈមមុខនឹងសាលារៀនដែលកាន់តែចាស់ទៅៗ ភាពចង្អៀតកុះករនៅតាមសាលាវិទ្យាល័យ ហើយនិងការចាំបាច់ក្នុងការកែធ្វើឲ្យអាគារសាលាមានគុណភាពស្មើនឹងខ្នាតគំរូសម្រាប់ពេលរញ្ជួយផែនដី ក្រុមប្រឹក្សាភិបាលប្រចាំក្រសួងអប់រំបានយល់ព្រមដាក់វិធានការប័ណ្ណប្រាក់រដ្ឋាភិបាល ចំនួន១កោដិ២០០លានដុល្លារសម្រាប់សង់និងកែជួសជុលសាលារៀនដែលប្រជាពលរដ្ឋនឹងត្រូវធ្វើការបោះឆ្នោតសម្រេច នៅថ្ងៃទី៤ខែវិច្ឆិកាឆ្នាំ២០០៨ខាងមុខនេះ។

សៈ ហេតុអ្វីបានជាក្រុមប្រឹក្សាភិបាលក្រសួងអប់រំសម្រេចចិត្តឲ្យដាក់វិធានការប័ណ្ណប្រាក់រដ្ឋាភិបាលសម្រាប់សាលានេះ?

ចៈ កន្លងមកថ្មីៗនេះ ក្រសួងអប់រំបានធ្វើការពិនិត្យមើលយ៉ាងល្អិតល្អន់ទៅលើស្ថានភាពសាលារៀននិងបន្ទប់រៀន។ ក្រសួងអប់រំក៏បានចំណាយពេលអស់រយៈពេលជាង២ឆ្នាំជួបពិភាក្សាជាមួយនិងទទួលយោបល់ពីសមាជិកក្នុងសហគមន៏រាប់ពាន់នាក់ដើម្បីរៀបចំផែនការមួយសម្រាប់កែជួសជុលសាលារៀនឲ្យប្រសើរឡើង។ ក្រសួងអប់រំបានទទួលយកយោបល់ទាំងអស់ពីសហគមន៏ហើយធ្វើអាទិភាពទៅលើការបារម្ភណ៏ធំៗទាំងឡាយរបស់សហគមន៏។

សៈ តើនៅក្នុងក្រសួងអប់រំឡុងប៊ីចនេះមានអ្វីខ្លះដែលត្រូវការជួសជុលនិងសង់បន្ថែមដែលសំខាន់ៗជាងគេ?

ចៈ ជាង៨០%នៃអាគារសាលារៀនបានសាងសង់ឡើងមុនឆ្នាំ១៩៧០។ ចំណុចទាំងឡាយខាងក្រោមនេះត្រូវការកែជួសជុលៈ

- ធ្វើផ្លូវសម្រាប់រទេះជនពិការដើម្បីឲ្យស្របតាមការតម្រូវពីច្បាប់
- បកថ្នាំដែលមានធាតុសំណនិងធាតុម៉្យាងដែលមិនឆេះ (អាស់បែស្តូស)
- កែឲ្យទាន់សម័យនូវសម្ភារៈបច្ចេកទេស ដូចជាកុំព្យូទ័រ និងហេដ្ឋារចនាសម្ព័នបណ្តាញទំនាក់ទំនងជាដើម
- ពង្រឹងគ្រឹសអាគារសាលាដែលអាចមានគ្រោះថ្នាក់នៅពេលរញ្ជួយផែនដី
- សង់សាលាវិទ្យាល័យថែមទៀតដើម្បីបន្ធូរភាពចង្អៀតកុះករ
- កែឲ្យទាន់សម័យបន្ទប់សិក្សាពិសោធន៏និងបន្ទប់រៀនផ្សេងៗ បណ្ណាល័យ បន្ទប់ទឹក ប្រព័ន្ធបំពង់បង្ហូរទឹកនិងដំបូលសាលា
- កែប្រព័ន្ធអគ្គីសនីយនិងទឹកដើម្បីជួយសន្សំសំចៃ

សៈ ចុះក្រែងរដ្ឋកាលីហ្វ័រនីញ៉ាបានផ្តល់ប្រាក់ជំនួយសម្រាប់ជួសជុលនិងសង់សាលារៀនហើយមែនឬទេ?

ចៈ មែន ប៉ុន្តែរដ្ឋជួយចេញតែស្មើនឹងចំនួនទឹកប្រាក់ដែលសាលាមានសម្រាប់សង់សាលាប៉ុណ្ណុះ។ ក្រសួងអប់រំយើងអាចទទួលបានប្រាក់ចំនួនប្រហែល $286,100,000 ពីរដ្ឋ

សៈ តើក្រសួងអប់រំដ៏ទៃដែលពុំមានប្រាក់សម្រាប់សង់សាលានឹងបានទទួលប្រាក់ជំនួយពីរដ្ឋដែរឬទេ?

ចៈ ទេ ប័ណ្ណប្រាក់រដ្ឋាភិបាលនេះនឹងផ្តល់ឲ្យតែក្រសួងអប់រំណាដែលបានទទួលការយល់ព្រមជាមុនក្នុងការមានសិទ្ធទទួលប័ណ្ណប្រាក់រដ្ឋាភិបាលនេះប៉ុណ្ណុះ

សៈ តើវិបត្តថវិការនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ាមានប៉ះពាល់ដល់ក្រសួងអប់រំឡុងប៊ីចដែរឬទេ?

ចៈ ក្រសួងអប់រំបានកាត់ថវិការចំនួនជាង $40 លានក្នុងឆ្នាំនេះថែមពីលើការកាត់ជាច្រើនពីមុនៗមកដោយសារតែវិបត្តថវិការរដ្ឋ។ ចំណុចមួយដែលល្អស្តីអំពីប្រាក់ជំនួយពីរដ្ឋនោះគឺការផ្តល់ប្រាក់ឲ្យស្មើនឹងប្រាក់ដែលក្រសួងអប់រំមានសម្រាប់ជួសជុលសាលា។

សៈ ដើម្បីឲ្យបានដឹងពត៏មានថែមទៀតអំពីវិធានការ K នេះតើត្រូវធ្វើយ៉ាងណា?

ចៈ សន្លឹកបោះឆ្នោតរបស់លោកអ្នកនឹងមានការវិភាគវែកញែកដោយមិនលំអៀង។ ដើម្បីឲ្យបានដឹងពត៏មានថែមទៀតអំពីវិធានការ **K** នេះ សូមចូលទៅវែបសាយ www.lbschools.net ហើយចុចលើ School Building Plan ។

ក្រដាសពត៏មាននេះផ្តល់ជូនលោកអ្នកសម្រាប់ជាពត៏មានប៉ុណ្ណុះ ហើយមិនមែនជាការជំរុញឲ្យបោះឆ្នោតទទួលយកវិធានការនេះទេ។